ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍
# វាលខ្យង
# សម្រាប់រយៈពេល ៣ ឆ្នាំ
# ( កក្កដា ២០១៩ - មិថុនា ២០២២ )

| | | |
|---|---|---|
| ឈ្មោះសហគមន៍នេសាទ | ៖ | វាលខ្យង |
| ភូមិ | ៖ | សំភិន |
| ឃុំ | ៖ | កំពង់ចាម |
| ស្រុក | ៖ | សំបូរ |
| ខេត្ត | ៖ | ក្រចេះ |

ខែមករា ឆ្នាំ២០១៩

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍
# វាលខ្យង
# សម្រាប់រយៈពេល ៣ ឆ្នាំ
# ( កក្កដា ២០១៩ - មិថុនា ២០២២ )

| | | |
|---|---|---|
| ឈ្មោះសហគមន៍នេសាទ | ៖ | វាលខ្យង |
| ភូមិ | ៖ | សំភិន |
| ឃុំ | ៖ | កំពង់ចាម |
| ស្រុក | ៖ | សំបូរ |
| ខេត្ត | ៖ | ក្រចេះ |

ខែមករា ឆ្នាំ២០១៩

# មាតិកា


១. ស្ថានភាពទូទៅ ........................................ ១
២. អំពីប្រជាសាស្ត្រ និងសេដ្ឋកិច្ចសង្គម ........................................ ២
ក .ប្រជាពលរដ្ឋ ........................................ ២
ខ .មុខរបរ ........................................ ២
៣. កន្លែងនេសាទ និងធនធានជលផលដែលមាននៅក្នុងកន្លែងនេសាទ ........................................ ៣
ក .ទីតាំង ........................................ ៣
ខ .ដែននេសាទ ........................................ ៣
គ .តំបន់ដែលមានលទ្ធភាពអាចបង្កើតកន្លែងអភិរក្ស ........................................ ៣
ឃ .ធនធានជលផល ........................................ ៤
៤. ការធ្វើនេសាទ ........................................ ៤
ក .អ្នកនេសាទ ........................................ ៤
ខ .ឧបករណ៍នេសាទ ........................................ ៤
គ. ការប៉ាន់ប្រមាណផលនេសាទចាប់បានប្រចាំឆ្នាំ ........................................ ៥
៥. ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ ........................................ ៥
ក.ទស្សនៈវិស័យ ........................................ ៥
ខ .គោលបំណងរួម ........................................ ៥
គ. គោលបំណងជាក់លាក់ ........................................ ៥
ឃ .ផែនការសកម្មភាពគ្រប់គ្រងកន្លែងនេសាទសហគមន៍ ........................................ ៦
ឃ.១ ធនធានជលផល និងអេកូឡូស៊ី ........................................ ៦
ឃ.២ ការគាំទ្រជីវភាពប្រជាពលរដ្ឋ ........................................ ៨
ឃ.៣ ការគ្រប់គ្រង ........................................ ១០
ង. ការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ ........................................ ១៣
ច .យុទ្ធសាស្ត្រ ........................................ ១៣
តារាងសង្ខេបផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍វាលខ្យងរយៈពេល៣ឆ្នាំ ........................................ ១៥
តារាងកម្មវិធីការងារប្រចាំឆ្នាំ (កក្កដា ២០១៩-មិថុនា ២០២២) ........................................ ២១

# ផែនការគ្រប់គ្រង
# កន្លែងនេសាទសហគមន៍

## ១. ស្ថានភាពទូទៅ

សហគមន៍នេសាទវាលខ្សង់ មានទីតាំងស្ថិតនៅក្នុងភូមិសំភិន ឃុំកំពង់ចាម ស្រុកសំបូរ ខេត្តក្រចេះ។ សហគមន៍នេសាទនេះ ត្រូវបានបង្កើតឡើងនៅឆ្នាំ១៩៩៤ ដោយមានការគាំទ្របច្ចេកទេស និងថវិកាពីខណ្ឌរដ្ឋបាលជលផលខេត្តក្រចេះ និងអង្គការអុកស្វាមអូស្ត្រាលី (CAA/Oxfam Australia)។ បន្ទាប់មកបានបោះឆ្នោតជ្រើសរើសគណៈកម្មការសហគមន៍នេសាទឡើងវិញ នៅថ្ងៃទី០៥ ខែមេសា ឆ្នាំ២០១៤ និងបានចុះកិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍រវាងខណ្ឌរដ្ឋបាលជលផល និងគណៈកម្មការសហគមន៍នេសាទចំនួន២អាណត្តិ លើកទី១ នៅថ្ងៃទី១១ ខែវិច្ឆការ ឆ្នាំ២០១៤ និងបានបន្តកិច្ចព្រមព្រៀងអាណត្តិទី២នៅថ្ងៃទី២៧ កញ្ញា ឆ្នាំ២០១៦ ដែលរៀបចំឡើងដោយខណ្ឌរដ្ឋបាលជលផលក្រចេះ និងគាំទ្រថវិកាដោយអង្គការអភិវឌ្ឍន៍ជនបទភូមិភាគឦសាន (NRD)។ ក្រៅពីនោះដោយមានការគាំទ្របច្ចេកទេស ថវិកាពីខណ្ឌរដ្ឋបាលជលផលក្រោមគម្រោងគ្រប់គ្រងធនធានទឹកចម្រុះទន្លេមេគង្គ (ដំណាក់កាលទី៣) សហគមន៍បានធ្វើបច្ចុប្បន្នភាពបញ្ជីឈ្មោះសមាជិកសហគមន៍នេសាទឡើងវិញ តាមរយៈកិច្ចប្រជុំនៅថ្ងៃទី១៣ ខែសីហា ឆ្នាំ២០១៨ ដោយសមាជិកដែលបានចុះក្នុងបញ្ជីជាផ្លូវការ សរុបចំនួន ១២៩ នាក់ ស្រីមានចំនួន៦៥ នាក់។ បន្ទាប់មកបានបោះឆ្នោតជ្រើសរើសគណៈកម្មការសហគមន៍ម្តងទៀតនៅថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៨ ដោយគណៈកម្មការដែលទើបជាប់ឆ្នោតថ្មីមានចំនួន១១នាក់ ក្នុងនោះស្រីចំនួន៣នាក់ បានរៀបចំរចនាសម្ព័ន្ធគ្រប់គ្រង និងបែងចែកតួនាទីនិងភារកិច្ចទទួលខុសត្រូវតាមការស្ម័គ្រចិត្ត និងឯកភាពគ្នាក្នុងចំណោមសមាជិកគណៈកម្មការទាំងអស់ និងបានរៀបចំធ្វើបច្ចុប្បន្នភាពផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ តាមរយៈកិច្ចប្រជុំថ្ងៃទី២២-២៣ ខែមករា ឆ្នាំ២០១៩ និងមហាសន្និបាតអនុម័តផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០១៩។

ទន្ទឹមនឹងសមិទ្ធផលដែលសម្រេចបានដូចខាងលើ សហគមន៍នេសាទនៅមានការជួបប្រទះនូវបញ្ហាប្រឈមនានាពាក់ព័ន្ធនឹងធនធានជលផលនិងអេកូឡូស៊ី ជីវភាពប្រជាពលរដ្ឋ និងការគ្រប់គ្រង៖

-បញ្ហាប្រឈមពាក់ព័ន្ធនឹងធនធានជលផលនិងអេកូឡូស៊ី រួមមានបរិមាណត្រីថយចុះ អន្លង់អភិរក្សកាន់តែរាក់ មានការកាប់ព្រៃតាមដងទន្លេសម្រាប់ចូលទូក ទឹកទន្លេកើតស្លែច្រើន បាក់ដីច្រាំងទន្លេ កោះ និងគ្រោះរាំងស្ងួត

-បញ្ហាប្រឈមពាក់ព័ន្ធនឹងជីវភាពប្រជាពលរដ្ឋ រួមមានប្រជាពលរដ្ឋគ្មានមុខរបរនិងមិនមានការងារធ្វើ បុរសលក់កំលាំងពលកម្មក្រៅភូមិ ចំនួនភ្ញៀវទេសចរមកលេងកោះមានការថយចុះ ខ្វះទុនបង្កើនមុខរបរ ខ្វះបច្ចេកទេសចិញ្ចឹមសត្វ និងដាំបន្លែ មានសត្វល្អិតបំផ្លាញដំណាំបន្លែ ការចិញ្ចឹមសត្វ (មាន់ ទា គោនិងក្របី)មានជម្ងឺ ផលិតផលកសិកម្មថយចុះ ខ្វះបច្ចេកទេសដាំដំណាំ ពិបាកលក់ផលិតផលកសិកម្ម គ្មានសាលាមត្តេយ្យសហគមន៍ បង្គន់តាមគ្រួសារមិនគ្រប់គ្រាន់ និងមិនមានផ្លូវលំសម្រាប់ផ្តល់ភាពងាយស្រួលក្នុងការដឹកផលិតផលកសិកម្មសម្រាប់ការធ្វើដំណើរមកសាលារៀនរបស់កុមារ និងសម្រាប់ទំនាក់ទំនងរវាងប្រជាជនរស់នៅក្នុងភូមិសំភិនខាងលិចនិងសំភិនខាងកើត

-បញ្ហាប្រឈមពាក់ព័ន្ធនឹងការគ្រប់គ្រង រួមមានបទល្មើសនេសាទ(ដូចជាឆក់ត្រីច្រើន ដាក់មងក្រឡាធំ វាយមងជាក្រុម វាយសន្ទូចប្រើនុយអប់ នេសាទត្រីនៅរដូវត្រីពង វាយមងរដូវត្រីពង) សមាជិកសហគមន៍នេសាទនៅពុំទាន់មាន

ការយល់ដឹងនិងចូលរួមការងារសហគមន៍ឱ្យបានសស្រាក់សស្រាំ នៅមានអ្នកមកពីខាងក្រៅសហគមន៍នេសាទលួចធ្វើនេសាទនៅកន្លែងអភិរក្សជាពិសេសនៅពេលយប់ សហគមន៍នេសាទចុះល្បាតមិនទាន់បានទៀងទាត់ដោយសារទូកសហគមន៍ចាស់និងយឺត គ្មានប្រេង និងខ្វះឧបករណ៍សម្ភារនានាសម្រាប់ល្បាត មិនទាន់មានទីស្នាក់ការសហគមន៍សម្រាប់ប្រតិបត្តិការ គណៈកម្មការសហគមន៍នេសាទពុំទាន់មានសមត្ថភាពគ្រប់គ្រាន់ក្នុងការដឹកនាំសហគមន៍នេសាទ សហគមន៍នៅតែគិតថាការងារគណៈកម្មការជាការងារបច្ចេកទេស និងជាតួនាទីរបស់បុរស ចំណែកស្ត្រីមានតួនាទីជាអ្នកថែទាំគ្រួសារ ការងារផ្ទះ និងលក់ដូរ ការចូលរួមរបស់ស្ត្រីក្នុងកិច្ចប្រជុំនានាមានចំនួនច្រើន តែការសម្រេចចិត្តនៅមានកម្រិត។

## ២. អំពីប្រជាសាស្ត្រ និងសេដ្ឋកិច្ចសង្គម

### ក. ប្រជាពលរដ្ឋ

ចំនួនប្រជាពលរដ្ឋសរុបនៅក្នុងសហគមន៍មានចំនួន ១១២៧ នាក់ ស្រី ៦០២ នាក់។ ប្រជាពលរដ្ឋក្នុងសហគមន៍នេសាទជាអ្នកកាន់សាសនាព្រះពុទ្ធ ១០០%។

ប្រជាពលរដ្ឋភូមិសំភិនមានស្ថានភាពដូចខាងក្រោមៈ

- ចំនួនស្ត្រីមេម៉ាយមាន ៣១នាក់
- ចំនួនជនពិការមាន ១៨នាក់ ស្រី១០ នាក់
- ចំនួនចាស់ជរាមាន ១៩ នាក់ ស្រី ១២ នាក់
- ចំនួនកុមារកំព្រាមាន ១៨ នាក់ ស្រី ២ នាក់
- ចំនួនអ្នកមានជំងឺរុំារ៉ៃមាន ២២ នាក់ ស្រី ១៦ នាក់
- កម្រិតសិក្សាអប់រំរួមមានអ្នកមិនចេះអក្សរមានចំនួន ១៥៤ នាក់ ស្រី ៦១ នាក់ បឋមសិក្សាចំនួន ១០០នាក់ ស្រី ៩៤ នាក់ មធ្យមសិក្សាចំនួន ៧៣ នាក់ និងថ្នាក់ឧត្តមសិក្សាចំនួន ៧នាក់ ស្រី ១នាក់។

### ខ. មុខរបរ

មុខរបរសំខាន់ៗរបស់ប្រជាពលរដ្ឋក្នុងតំបន់សហគមន៍នេះរួមមានៈ

- ធ្វើនេសាទជាលក្ខណៈគ្រួសារចំនួន ២២៧ គ្រួសារ
- ធ្វើស្រែវស្សាចំនួន ១៥១ គ្រួសារ ទំហំ ១៥០ ហិកតា
- ដាំបន្លែចំនួន ១៥ គ្រួសារ
- ធ្វើចំការចំនួន ១០គ្រួសារ ទំហំ២០ ហិកតា
- លក់ដូរចាប់ហួយចំនួន ២១ គ្រួសារ។

## ៣. កន្លែងនេសាទ និងធនធានជលផលដែលមាននៅក្នុងកន្លែងនេសាទ

ក. ទីតាំង

កន្លែងនេសាទសហគមន៍វាលខ្យងជាទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ។ កន្លែងនេសាទសហគមន៍វាលខ្យង ស្ថិតនៅតាមដងទន្លេមេគង្គមានទំហំ ៦៨៩,០៨ ហិកតា និងមាននិយាមការដូចមានចែងនៅក្នុងកិច្ចព្រមព្រៀង។

មានព្រំប្រទល់ ៖

- ខាងជើងទល់នឹងកន្លែងនេសាទសហគមន៍កោះស័ក្តសិទ្ធិ
- ខាងត្បូងទល់នឹងភូមិកែងប្រាសាទ ឃុំសំបូរ ស្រុកសំបូរ ខេត្តក្រចេះ
- ខាងកើតទល់នឹងកោះរងាវ ក្នុងភូមិសំភិន ឃុំកំពង់ចាម ស្រុកសំបូរ ខេត្តក្រចេះ
- ខាងលិចទល់នឹងកន្លែងនេសាទសហគមន៍កាំងយាយម៉ៅ

ខ. ដែននេសាទ

កន្លែងនេសាទសហគមន៍វាលខ្យង ស្ថិតនៅតាមដងទន្លេមេគង្គ មានកោះ និង ព្រៃលិចទឹកដុះរាយនៅតាមមាត់ច្រាំងទន្លេ។ កន្លែងនេសាទសហគមន៍វាលខ្យង មានអន្លង់ចំនួន ២ ព្រែកចំនួន ៤ និង កោះចំនួន៣៖

| | | |
|---|---|---|
| - អន្លង់វាលខ្យង | ទំហំ ៦ ហិកតា | មានទឹកពេញមួយឆ្នាំ |
| - អន្លង់កន្ទុយកោះដំឡូងធំ | ទំហំ ២,៦ ហិកតា | មានទឹកពេញមួយឆ្នាំ |
| - ព្រែកស្ដេក | ប្រវែង ២.០០០ម៉ែត្រ | មានទឹកពីខែកក្កដាដល់តុលា |
| - ព្រែកយាយខឿន | ប្រវែង ១.០០០ម៉ែត្រ | មានទឹកពីខែកក្កដាដល់តុលា |
| - ព្រែកអណ្ដូង | ប្រវែង ១.៥០០ម៉ែត្រ | មានទឹកពីខែកក្កដាដល់តុលា |
| - ព្រែកខ្មោច | ប្រវែង ១.០០០ម៉ែត្រ | មានទឹកពីខែកក្កដាដល់តុលា |
| - កោះដំឡូងធំ | ទំហំ ១០ហិកតា | |
| - កោះដំឡូងតូច | ទំហំ ៥ហិកតា | |
| - កោះដូនរាជ | ទំហំ ១ហិកតា | |

គ. តំបន់ដែលមានលទ្ធភាពអាចបង្កើតកន្លែងអភិរក្ស

អន្លង់វាលខ្យង ទំហំ ៦ ហិកតា និង អន្លង់កន្ទុយកោះដំឡូងធំ ទំហំ២,៦ហិកតា ជាតំបន់ដែលមានសក្ដានុពលសម្រាប់អភិរក្សត្រីមេពូជ តាមការសម្រេចរបស់មហាសន្និបាត។

ឃ. ធនធានជលផល

ឃ.១. ប្រភេទត្រី ៖

ត្រីខ្យា ត្រីឆ្លាំង ត្រីទ្រនេល ត្រីឆ្កោក ត្រីក្រសក់ ត្រីក្អែក ត្រីក្ដី ត្រីក្រាយ ត្រីឆ្ពោរ ត្រីរ៉ស់ ត្រីអំបុង ត្រីសណ្ដាយ ត្រីក្លាំងហាយ ត្រីប្រា ត្រីកែស ត្រីប្រាកណ្ដុរ ត្រីពោធិ៍ ត្រីព្រលូង ត្រីប៉ាវ៉ា ត្រីដំរី ត្រីប៉ាស៊ីអី ត្រីផ្ទក់ ត្រីឆ្ដូញ ត្រីខ្ទឹង ត្រីរៀល ត្រីក្រឡង់ ត្រីកញ្ចុះ ត្រីគ្រំ ត្រីក្រាញ់ ត្រីកន្ទ្រប់ ត្រីចេក ត្រីសារិកាកែវ ត្រីឆ្ពិន ត្រីកាហែ ត្រីច្រកែង ត្រីចង្វារ ត្រីអណ្ដែង ត្រីស្លឹកឫស្សី ត្រីកំភ្លាវ ត្រីតាអោន ត្រីគល់រាំង ត្រីបបែល ត្រីលលកស ត្រីស្នក់ ត្រីខ្មាន់ ត្រីកាទឹម ត្រីក្រុស ត្រីកញ្ជ្រូក ត្រីអាចម៍កុក ត្រីកំបុតច្រមុះ ត្រីកញ្ជនជ័យ ត្រីក្របី ត្រីកែ ត្រីឈ្មៀត ត្រីកំពត ត្រីផ្ទោង ត្រីអន្ទង់ ត្រីខ្លា ត្រីប្រម៉ា ត្រីរាហ៊ូ ត្រីអណ្ដាតឆ្កែ ត្រីស្លាត ត្រីននោងល្ងឹង ត្រីកន្ទ្រងប្រេង ត្រីរមាស ត្រីតាយ៉ូ។

ឃ.២. ប្រភេទវារីសត្វ ៖ អណ្ដើក កន្ធាយ ល្មិច និង សត្វផ្សោត។

ឃ.៣. ព្រៃលិចទឹក និងវារីរុក្ខជាតិ

ដើមរៃ ដើមអណ្ដែង ដើមអញ្ចោង ដើមអញ្ចៃ ដើមទន្លា ដើមត្រស់ ដើមរាំង ដើមក្ដុល ដើមផ្ដៅ ដើមត្រែង ដើមស្លួត និងដើមបបុស។

## ៤. ការធ្វើនេសាទ

ក. អ្នកនេសាទ

- អ្នកនេសាទជាសមាជិកសហគមន៍នេសាទមានចំនួន ៧៧ នាក់ ស្រី ៣៩ នាក់
- អ្នកនេសាទមិនមែនជាសមាជិកសហគមន៍នេសាទក្នុងសហគមន៍មានចំនួន ៧០ នាក់
- ប៉ាន់ស្មានអ្នកនេសាទមិនមែនជាសមាជិកដែលមកពីក្រៅសហគមន៍ចំនួន ២០ នាក់ ស្រី ១០ នាក់។

ខ. ឧបករណ៍នេសាទ

| ប្រភេទ ឧបករណ៍ | ឯកតា | ចំនួន | | | ទំហំ ប្រវែង | | | រដូវប្រើប្រាស់ ឧបករណ៍ នេសាទ |
|---|---|---|---|---|---|---|---|---|
| | | សមាជិក | មិនមែន សមាជិក | អ្នកខាង ក្រៅភូមិ | សមាជិក | មិនមែនសមាជិក | អ្នកខាង ក្រៅភូមិ | |
| សំណាញ់ | វង់ | ៨០ | ៦០ | | ប្រវែង៤ម ក្រឡា ២-១៥សម | ប្រវែង៤ម ក្រឡា ២-១៥សម | | មករា-ធ្នូ |
| បង្កៃ | ផ្លែ | ៥០០ | ៤០០ | | ផ្លែលេខ៦-៨ | ផ្លែលេខ៦-៨ | | កក្កដា-តុលា |
| បង្កង | ផ្លែ | ១៥០០ | ១៥០០ | | ផ្លែលេខ១០-១២ | ផ្លែលេខ១០-១២ | | កក្កដា-តុលា |
| សន្ទូចរនង | សាង (១០០ផ្លែ) | ៧០ | ៧០ | | ផ្លែលេខ ១២-១៤ | ផ្លែលេខ ១២-១៤ | | កក្កដា-តុលា |
| លប | គ្រឿង | ២៥០ | ២០០ | | មុខ០,៨ម បណ្ដោយ១,៨ម | មុខ០,៨ម បណ្ដោយ១,៨ម | | មិថុនា-តុលា |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| ចាន់ | គ្រឿង | ៤០ | ៣០ | | មុខ០,៣ម បណ្តោយ១ម | មុខ០,៣ម បណ្តោយ១ម | | មិថុនា-តុលា |
| មង | ត្បូង (៨០ម) | ៥០ | ៨០ | ២០ | ក្រឡា៣-៤សម | ក្រឡា៣-៤សម | ក្រឡា ១២-១៥សម | មករា-ធ្នូ |

ម=ម៉ែត្រ សម=សង្ទីម៉ែត្រ

ប្រភេទទូកកាណូត

| ប្រភេទទូកកាណូត | ចំនួន (ទូក) | | | ចំណុះ(គីឡូក្រាម) | | | កម្លាំងសេះ | | |
|---|---|---|---|---|---|---|---|---|---|
| | សមាជិក | មិនមែនសមាជិក | អ្នកខាងក្រៅភូមិ | សមាជិក | មិនមែនសមាជិក | អ្នកខាងក្រៅភូមិ | សមាជិក | មិនមែនសមាជិក | អ្នកខាងក្រៅភូមិ |
| ទូកមានម៉ាស៊ីន | ៩០ | ៩០ | ១០ | ៣០០-៤០០ | ៣០០-៤០០ | ៣០០-៤០០ | ១៣-១៨ | ១៣-១៨ | ១៣-១៨ |

គ. ការប៉ាន់ប្រមាណផលនេសាទចាប់បានប្រចាំឆ្នាំ

| ប្រភេទផលនេសាទ | បរិមាណផលនេសាទចាប់បានគិតជាមធ្យមក្នុង១គ្រួសារ (គីឡូក្រាម) | | |
|---|---|---|---|
| | រដូវប្រាំង | រដូវវស្សា | សរុបប្រចាំឆ្នាំ |
| ត្រី | ៣៧៩,៣០ | ៥៨៦,៨៦ | ៩១៦,១៦ |

## ៥. ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍

ក.ទស្សនៈវិស័យ

សហគមន៍នេសាទ វាលខ្សាង មានទស្សនវិស័យរួមចំណែកគ្រប់គ្រងធនធានជលផលប្រកប ដោយសមធម៌ និងចីរភាព ដើម្បីរួមចំណែកកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋ ។

ខ. គោលបំណងរួម

ដើម្បីសម្រេចបាននូវទស្សនវិស័យខាងលើ សហគមន៍នេសាទ មានគោលបំណងរួមដូចខាងក្រោម៖

- ចូលរួមលុបបំបាត់បទល្មើសនេសាទដើម្បីធ្វើឱ្យផលត្រីមានការកើនឡើង
- សមាជិកសហគមន៍នេសាទមានមុខរបរច្បាស់លាស់ និងបង្កើនប្រាក់ចំណូល
- សមាជិកសហគមន៍នេសាទមានការគោរពច្បាប់ជលផល និងចូលរួមការពារធនធានជលផល។

គ. គោលបំណងជាក់លាក់

- ការពារធនធានជលផលតាមរយៈការផ្សព្វផ្សាយច្បាប់ជលផល និងដាំព្រៃលិចទឹកតាមច្រាំងទន្លេដែលជាជម្រកត្រី
- បង្កើនជម្រើសមុខរបរចិញ្ចឹមជីវិតដល់សមាជិកសហគមន៍នេសាទ តាមរយៈការចិញ្ចឹមសត្វ ត្រី ដាំបន្លែដោយមានបច្ចេកទេសនិងមានទីផ្សារសហគមន៍សម្រាប់កសិផល

- កាត់បន្ថយបទល្មើសនេសាទ តាមរយៈការផ្សព្វផ្សាយ និងចុះល្បាតដោយមានកិច្ចសហការនិងរាយការណ៍ដល់អាជ្ញាធរដែនដីនិងអ្នកពាក់ព័ន្ធ។

### ឃ. ផែនការសកម្មភាពគ្រប់គ្រងកន្លែងនេសាទសហគមន៍

### ឃ.១. ធនធានជលផល និងអេកូឡូស៊ី

### ឃ.១.១. ផែនការប្រើប្រាស់ឧបករណ៍នេសាទ

ផែនការប្រើប្រាស់ឧបករណ៍នេសាទនៅក្នុងកន្លែងនេសាទសហគមន៍ គឺគិតគូរអំពីប្រភេទកន្លែងនេសាទ ប្រភេទ ទំហំ ប្រវែងចំនួនឧបករណ៍នេសាទ ចំនួនអ្នកនេសាទ និងរដូវនេសាទត្រូវបានរៀបចំខាងក្រោម៖

| ឈ្មោះ/ទីតាំងកន្លែងនេសាទ | ពេលវេលាធ្វើនេសាទ | ឧបករណ៍នេសាទអនុញ្ញាតឱ្យប្រើ | | | ការប៉ាន់ស្មានថវិកា (ដុល្លារ) |
|---|---|---|---|---|---|
| | | ប្រភេទ | ទំហំ / ប្រវែង | ចំនួន | |
| ១. នៅតាមដងទន្លេមេគង្គនៅខាងក្រៅអន្លង់អភិរក្សសហគមន៍ | មករា - ធ្នូ | សំណាញ់ | ក្រឡា ៥.៥-១៦ ស.ម | ៨០ វង់ | ១៥០-(៥០/ឆ្នាំ សម្រាប់ការងារផ្សព្វផ្សាយ) |
| | មករា - ធ្នូ | សន្ទូចរនង | ផ្លែលេខ៩-១២ | ៣៥០ សាង (១០០ផ្លែ/សាង) | |
| | មិថុនា - ធ្នូ | លប | មុខ១.២ ម ប្រវែង២ម | ៣៥០ លប | |
| | មិថុនា - ធ្នូ | ចាន់ | មុខ ០,៤ ម | ២០ ចាន់ | |
| | មិថុនា - ធ្នូ | សៃយឺន | ០,៨ម-១,៨ម | ១០ គ្រឿង | |
| | មិថុនា - ធ្នូ | ទ្រូ | | ១០ គ្រឿង | |
| | មិថុនា - ធ្នូ | លាន់ | | ១៥០ គ្រឿង | |
| | មិថុនា - ធ្នូ | ឈ្នាងត្រាំ | | ១០ គ្រឿង | |

ម=ម៉ែត្រ សម=សង្ទីម៉ែត្រ

### ឃ.១.២. ផែនការកំណត់ និងរៀបចំកន្លែងអភិរក្សសហគមន៍

ផែនការកំណត់ និងរៀបចំកន្លែងអភិរក្សសហគមន៍ត្រូវបានរៀបចំខាងក្រោម៖

| ឈ្មោះ / ទីតាំង | ទំហំ ហិកតា | ប្រភេទនៃការអភិរក្ស | សកម្មភាព | ការប៉ាន់ស្មានថវិកា (ដុល្លារ) | ថ្ងៃខែឆ្នាំចាប់ផ្តើម | ថ្ងៃខែឆ្នាំបញ្ចប់ |
|---|---|---|---|---|---|---|
| អន្លង់វាលខ្យង | ៦ | • ត្រីគ្រប់ប្រភេទ<br>• សត្វទឹកគ្រប់ប្រភេទ<br>• ព្រៃលិចទឹកគ្រប់ប្រភេទ | ដាក់ពោង និងស្លាកសញ្ញាតាមអន្លង់ (៤x២០០) | ៨០០ | កក្កដា ២០១៩ | មិថុនា ២០២២ |
| អន្លង់កន្ទុយកោះដំឡូងធំ | ២,៦ | | តម្លើងផ្ទាំងផ្សព្វផ្សាយអំពីច្បាប់ជលផល និងការអភិរក្ស (២x២០០) | ៤០០ | | |
| | | | លែងកូនត្រីពូជ៣លើក (៣លើកx៥០០) | ១.៥០០ | | |

ឃ.១.៣. ផែនការបោះបង្គោលព្រំប្រទល់ និងផ្ទាំងប៉ាណូផែនទីកន្លែងនេសាទសហគមន៍

ផែនការបោះបង្គោលព្រំប្រទល់ និងផ្ទាំងប៉ាណូផែនទីកន្លែងនេសាទសហគមន៍ត្រូវបានរៀបចំខាងក្រោម៖

| ឈ្មោះ / ទីតាំង | សកម្មភាព | ចំនួន | ការប៉ាន់ស្មានថវិកា(ដុល្លារ) | ថ្ងៃ ខែ ឆ្នាំ ចាប់ផ្តើម | ថ្ងៃ ខែ ឆ្នាំ បញ្ចប់ |
|---|---|---|---|---|---|
| ក្បែរវត្តវាលខ្សាង | រៀបចំ និងលើកផ្ទាំងប៉ាណូផែនទីកន្លែងនេសាទសហគមន៍ (ឱ្យស្ត្រីនិងបុរសជាគណៈកម្មការសហគមន៍នេសាទចូលរួមសម្រេចចិត្តក្នុងការកំណត់ទីតាំងបោះបង្គោលព្រំប្រទល់) | ១ ផ្ទាំង | ៣០០ | តុលា ២០១៩ | ធ្នូ ២០១៩ |

ឃ.១.៤. ផែនការគ្រប់គ្រងព្រៃលិចទឹក

ផែនការគ្រប់គ្រងព្រៃលិចទឹក ត្រូវបានរៀបចំខាងក្រោម៖

| ឈ្មោះទីតាំង | ទំហំ (ហិកតា) | ប្រភេទកូនឈើដែលត្រូវដាំ និងការពារ | សកម្មភាព | ការប៉ាន់ស្មានថវិកា (ដុល្លារ) | ថ្ងៃខែឆ្នាំ ចាប់ផ្តើម | ថ្ងៃខែឆ្នាំ បញ្ចប់ |
|---|---|---|---|---|---|---|
| ដាំតាមច្រាំងទន្លេ មាត់អូរ | ចាប់ពីដើមភូមិដល់ចុងភូមិ | ព្រៃលិចទឹកដែលត្រូវការពាររួមមាន ត្រែងរំ គ្រស់ រាំង ទន្លា | • ប្រជុំផ្សព្វផ្សាយពីផលប្រយោជន៍ព្រៃលិចទឹក (ស្ត្រីជាគណៈកម្មការសហគមន៍ នេសាទចូលរួមផ្សព្វផ្សាយពីផលប្រយោជន៍ព្រៃលិចទឹក ការពារព្រៃលិចទឹក និងដាក់ស្លាកសញ្ញាសម្គាល់)<br>• ការពារព្រៃលិចទឹកដែលមានស្រាប់<br>• ដាក់ស្លាកសញ្ញាហាមកាប់ព្រៃលិចទឹក និងស្លាកសញ្ញាសម្គាល់<br>• ដាំព្រៃលិចទឹក<br>• ចុះល្បាតជាប្រចាំ | ៣០០ | កក្កដា ២០១៩ | មិថុនា ២០២២ |

ឃ.២. ការគាំទ្រជីវភាពប្រជាពលរដ្ឋ

ឃ.២.១. ផែនការមុខរបរបង្កើនប្រាក់ចំណូល

ផែនការមុខរបរបង្កើនប្រាក់ចំណូលត្រូវបានរៀបចំខាងក្រោម៖

| ប្រភេទមុខរបរ | សកម្មភាព | ប្រភេទពូជ | បរិមាណ | ការប៉ាន់ស្មានថវិកា (ដុល្លារ) | ថ្ងៃខែឆ្នាំចាប់ផ្តើម | ថ្ងៃខែឆ្នាំប្រមូលផល |
|---|---|---|---|---|---|---|
| ចិញ្ចឹមមាន់តាមបច្ចេកទេសជាលក្ខណៈគ្រួសារ | • ជ្រើសរើសគ្រួសារ<br>• បណ្តុះបណ្តាលពីបច្ចេកទេសចិញ្ចឹម<br>• ផ្តល់ពូជ និងសម្ភារ<br>• តាមដានត្រួតពិនិត្យ | ក្នុងស្រុក | ២០គ្រួសារ (២០០ក្បាលx៥) | ១.០០០ | កក្កដា ២០១៩ | មិថុនា ២០២២ |
| ចិញ្ចឹមទាតាមបច្ចេកទេសជាលក្ខណៈគ្រួសារ | • ជ្រើសរើសគ្រួសារ<br>• បណ្តុះបណ្តាលពីបច្ចេកទេសចិញ្ចឹម<br>• ផ្តល់ពូជ និងសម្ភារ<br>• តាមដានត្រួតពិនិត្យ | ក្នុងស្រុក | ១០គ្រួសារ (១០០ក្បាលx៥) | ៥០០ | កក្កដា ២០១៩ | មិថុនា ២០២២ |
| ចិញ្ចឹមគោតាមបច្ចេកទេសជាលក្ខណៈគ្រួសារ | • ជ្រើសរើសគ្រួសារ<br>• បណ្តុះបណ្តាលពីបច្ចេកទេសចិញ្ចឹមគោរ<br>• ផ្តល់ពូជ និងសម្ភារ<br>• តាមដានត្រួតពិនិត្យ | ក្នុងស្រុក | ២៥គ្រួសារ (២៥ក្បាលx ៣០០) | ៧.៥០០ | កក្កដា ២០១៩ | មិថុនា ២០២២ |
| ចិញ្ចឹមក្របីតាមបច្ចេកទេសជាលក្ខណៈគ្រួសារ | • ជ្រើសរើសគ្រួសារ<br>• បណ្តុះបណ្តាលពីបច្ចេកទេសចិញ្ចឹមក្របី<br>• ផ្តល់ពូជ និងសម្ភារ<br>• តាមដានត្រួតពិនិត្យ | ក្នុងស្រុក | ២៥គ្រួសារ (២៥ក្បាលx ៣០០) | ៧.៥០០ | កក្កដា ២០១៩ | មិថុនា ២០២២ |
| ចិញ្ចឹមជ្រូកតាមបច្ចេកទេសជាលក្ខណៈគ្រួសារ | • ជ្រើសរើសគ្រួសារ<br>• បណ្តុះបណ្តាលបច្ចេកទេសចិញ្ចឹមជ្រូក<br>• ផ្តល់ពូជ និងសម្ភារ<br>• តាមដានត្រួតពិនិត្យ | ក្នុងស្រុក | ៤០គ្រួសារ (៨០ក្បាលx ៥០) | ៤.០០០ | កក្កដា ២០១៩ | មិថុនា ២០២២ |
| សួនបន្លែតាមលក្ខណៈគ្រួសារ | • ជ្រើសរើសគ្រួសារកសិករ<br>• បណ្តុះបណ្តាលបច្ចេកទេសធ្វើសួន បន្លែ<br>• ចែកគ្រាប់ពូជ /អនុវត្ត<br>• តាមដានត្រួតពិនិត្យ | បន្លែ ៥មុខ៖ (ស្ពៃ ត្រកួន ននោង សណ្តែកកួរ ត្រប់វែង) | ២០គ្រួសារ (២០x ៥០) | ១.០០០ | កក្កដា ២០១៩ | មិថុនា ២០២២ |

| ប្រភេទមុខរបរ | សកម្មភាព | ប្រភេទពូជ | បរិមាណ | ការប៉ាន់ស្មានថវិកា (ដុល្លារ) | ថ្ងៃខែឆ្នាំចាប់ផ្តើម | ថ្ងៃខែឆ្នាំប្រមូលផល |
|---|---|---|---|---|---|---|
| បណ្តុះផ្សិត | • ជ្រើសរើសគ្រួសារកសិករ<br>• បណ្តុះបណ្តាលបច្ចេកទេសបណ្តុះផ្សិត និងធ្វើមេផ្សិត<br>• អនុវត្តផ្ទាល់<br>• តាមដានត្រួតពិនិត្យ | ផ្សិតចំបើង និង ផ្សិតអំបោះ | ៣០ គ្រួសារ (៣០x ៥០) | ១.៥០០ | កក្កដា ២០១៩ | មិថុនា ២០២២ |
| បណ្តុះបណ្តាលបច្ចេកទេសធ្វើស្រែ និងស្រែបង្ហាញ | • ជ្រើសរើសគ្រួសារកសិករ<br>• បណ្តុះបណ្តាលបច្ចេកទេស<br>• ចែកពូជ /អនុវត្តផ្ទាល់<br>• តាមដានត្រួតពិនិត្យ | ស្រូវស្រាល | ១០០ គ្រួសារ (១០០x ១០០) | ១០.០០០ | កក្កដា ២០១៩ | មិថុនា ២០២២ |

### ឃ.២.២. ផែនការអភិវឌ្ឍន៍វារីវប្បកម្ម

ផែនការអភិវឌ្ឍន៍វារីវប្បកម្ម ត្រូវបានរៀបចំខាងក្រោម៖

| ប្រភេទវារីវប្បកម្ម | សកម្មភាព | ចំនួន | បរិមាណ | ការប៉ាន់ស្មានថវិកា (ដុល្លារ) | ថ្ងៃខែឆ្នាំចាប់ផ្តើម | ថ្ងៃខែឆ្នាំប្រមូលផល |
|---|---|---|---|---|---|---|
| ចិញ្ចឹមត្រី អណ្តែងក្នុងអាងតាមបច្ចេកទេសជាលក្ខណៈគ្រួសារ | • ជ្រើសរើសកសិករស្ម័គ្រចិត្ត<br>• បណ្តុះបណ្តាលបច្ចេកទេសចិញ្ចឹមត្រីអណ្តែង<br>• រៀបចំស្រះចិញ្ចឹមត្រី<br>• ផ្តល់កូនត្រី<br>• តាមដានត្រួតពិនិត្យ | ស្រះប្លាស្ទិក ឬ អាងស៊ីម៉ង់ចំនួន០១ក្នុងមួយគ្រួសារ (ទំហំ ៤មx៦មx១ម) | ៥គ្រួសារ (៥គ្រួសារx ៥០០) | ២.៥០០ | កក្កដា ២០១៩ | មិថុនា ២០២២ |

### ឃ.២.៣. ផែនការរៀបចំ និងពង្រឹងក្រុមសន្សំប្រាក់

ផែនការរៀបចំ និងពង្រឹងក្រុមសន្សំប្រាក់ ត្រូវបានរៀបចំខាងក្រោម៖

| ប្រភេទមុខរបរ | សកម្មភាព | ការប៉ាន់ស្មានថវិកា (ដុល្លារ) | ថ្ងៃខែឆ្នាំចាប់ផ្តើម | ថ្ងៃខែឆ្នាំបញ្ចប់ |
|---|---|---|---|---|
| បង្កើតក្រុមសន្សំប្រាក់ចំនួន ១ ក្រុមបន្ថែម | • ផ្សព្វផ្សាយទស្សនៈក្រុមសន្សំដល់សហគមន៍<br>• ជ្រើសរើសអ្នកទទួលផល<br>• បោះឆ្នោតជ្រើសរើសប្រធានក្រុម<br>• បង្កើតគោលការណ៍ និងបទបញ្ជាផ្ទៃក្នុង<br>• ផ្តល់ទុនដល់ក្រុម<br>• តាមដាន ត្រួតពិនិត្យ | ៣០០ | កក្កដា ២០១៩ | មិថុនា ២០២២ |

| | | | | |
|---|---|---|---|---|
| ពង្រឹងក្រុមសន្សំប្រាក់ដែលមានស្រាប់ ១ក្រុម | • ផ្សព្វផ្សាយទស្សនៈទានក្រុមសន្សំដល់សហគមន៍<br>• ជ្រើសរើសអ្នកទទួលផលបន្ថែម<br>• ពិនិត្យ និងកែសម្រួលបទបញ្ជាផ្ទៃក្នុង<br>• ផ្តល់ទុនបន្ថែមដល់ក្រុម<br>• តាមដានត្រួតពិនិត្យ | ២០០ | កក្កដា ២០១៩ | មិថុនា ២០២២ |

ឃ.២.៤. ផែនការសេវាសហគមន៍ និងហេដ្ឋារចនាសម្ព័ន្ធខ្នាតតូច

ផែនការសេវាសហគមន៍ និងហេដ្ឋារចនាសម្ព័ន្ធខ្នាតតូច ត្រូវបានរៀបចំខាងក្រោម៖

| សកម្មភាព | ចំនួន | ការប៉ាន់ស្មានថវិកា(ដុល្លារ) | ថ្ងៃខែឆ្នាំចាប់ផ្តើម | ថ្ងៃខែឆ្នាំបញ្ចប់ |
|---|---|---|---|---|
| ជួសជុលផ្លូវលំក្នុងភូមិប្រវែង ៤.០០០ ម៉ែត្រ | ១ ខ្សែ | ៤០.០០០ | កក្កដា ២០១៩ | មិថុនា ២០២២ |
| ដាក់លូកាត់ផ្លូវ | ១ កន្លែង | ១.៥០០ | កក្កដា ២០១៩ | មិថុនា ២០២២ |
| សាងសង់ផ្សារសហគមន៍ | ១ កន្លែង | ៥.០០០ | កក្កដា ២០១៩ | មិថុនា ២០២២ |
| សាងសង់សាលាមតេយ្យ | ១ ខ្នង | ១០.០០០ | កក្កដា ២០១៩ | មិថុនា ២០២២ |
| សាងសង់បង្គន់អនាម័យក្នុងសាលាមតេយ្យ | ២ បង្គន់ (២បង្គន់x២០០) | ៤០០ | កក្កដា ២០១៩ | មិថុនា ២០២២ |

ឃ.៣. ការគ្រប់គ្រង

ឃ.៣.១. ផែនការសកម្មភាពចុះល្បាតទប់ស្កាត់បទល្មើស

ផែនការសកម្មភាពចុះល្បាតទប់ស្កាត់បទល្មើស ត្រូវបានរៀបចំខាងក្រោម៖

| សកម្មភាព | តម្រូវការសម្ភារ | ចំនួន | ការប៉ាន់ស្មានថវិកា (ដុល្លារ) | ថ្ងៃខែឆ្នាំចាប់ផ្តើម | ថ្ងៃខែឆ្នាំបញ្ចប់ |
|---|---|---|---|---|---|
| សហគមន៍ចុះល្បាតដោយខ្លួនឯង | | ៨ដង/១ខែ (៨ដងx១២ខែx៣x២៥) | ៧.២០០ | កក្កដា ២០១៩ | មិថុនា ២០២២ |
| ផ្តល់សម្ភារល្បាត១ឈុត | អាវពោង | ១២ អាវ | ១.០០០ | កក្កដា ២០១៩ | មិថុនា ២០២២ |
| | អាវភ្លៀង | ១២ អាវ | | | |
| | គោមបំភ្លឺពាក់ក្បាល | ២ គោម | | | |
| | វិទ្យុទាក់ទង | ២ គ្រឿង | | | |
| | កែវយឺត | ២ គ្រឿង | | | |
| | ម៉ាស៊ីនថត | ១ គ្រឿង | | | |
| | អង្រឹង | ១២ | | | |
| | តង់គ្របទូក ៤មគុណ៦ម | ២ | | | |

| | | | | | |
|---|---|---|---|---|---|
| | សម្ភារត្រួតពិនិត្យទឹក | ១គ្រឿង | | | |
| | ស្លាបចក្រ | ៦គ្រឿង | | | |
| | សោរសម្រាប់ជួសជុលទូក | ១សម្រាប់ | | | |
| | សោរច្រវាក់ចាក់ទូក | ២ ឈុត | | | |
| | អាវយឺត | ២៤ អាវ | | | |
| ទិញទូកស្ពាច់ម៉ាស៊ីន | | ២ គ្រឿង | ៣.០០០ | កក្កដា ២០១៩ | មិថុនា ២០២២ |
| ប្រេងសម្រាប់ល្បាត | | ៨០ លីត្រ/ខែ (៨០លីត្រx៣៦ខែx១) | ២.៨៨០ | កក្កដា ២០១៩ | មិថុនា ២០២២ |
| សេវាជួសជុលនិងថែទាំទូក និងម៉ាស៊ីន | | ២ដង/ឆ្នាំ (៦ដងx១០០) | ៦០០ | កក្កដា ២០១៩ | មិថុនា ២០២២ |
| សាងសង់ទីស្នាក់ការសហគមន៍ (ដីសាលាឆទាន) | | ១ កន្លែង | ៣.០០០ | សីហា ២០១៩ | ធ្នូ ២០១៩ |

### ឃ.៣.២. ផែនការពង្រឹងគណៈកម្មការសហគមន៍នេសាទ

ផែនការពង្រឹងគណៈកម្មការសហគមន៍នេសាទ ត្រូវបានរៀបចំខាងក្រោមៈ

| សកម្មភាព | ចំនួន | ការប៉ាន់ស្មានថវិកា (ដុល្លារ) | ថ្ងៃខែឆ្នាំចាប់ផ្តើម | ថ្ងៃខែឆ្នាំបញ្ចប់ |
|---|---|---|---|---|
| ប្រជុំប្រចាំខែរបស់គណៈកម្មការសហគមន៍នេសាទ | ១ដង/១ខែ (៣៦ដងx១០) | ៣៦០ | កក្កដា ២០១៩ | មិថុនា ២០២២ |
| ចូលរួមប្រជុំប្រចាំខែជាមួយក្រុមប្រឹក្សាឃុំ | ១ដង/១ខែ (៣៦ដងx១០) | ៣៦០ | កក្កដា ២០១៩ | មិថុនា ២០២២ |
| បណ្តុះបណ្តាលអំពីរបៀបធ្វើកំណត់ហេតុ សរសេរលិខិតរដ្ឋបាលរបាយការណ៍ និងរៀបចំទុកឯកសារ | ១លើក/១ឆ្នាំ (៣លើកx២០) | ៦០ | កក្កដា ២០១៩ | មិថុនា ២០២២ |
| បណ្តុះបណ្តាលអំពីការដោះស្រាយទំនាស់ | | ៦០ | | |
| បណ្តុះបណ្តាលអំពីភាពជាអ្នកដឹកនាំ និងការគ្រប់គ្រង | | ៦០ | | |
| បណ្តុះបណ្តាលអំពីការរៀបចំផែនការសកម្មភាពការងារ | | ៦០ | | |
| បណ្តុះបណ្តាលអំពីការកត់ត្រាចំណាយចំណូល | | ៦០ | | |
| បណ្តុះបណ្តាលអំពីការសរសេរសំណើថវិកា | | ៦០ | | |

### ឃ.៣.៣. ផែនការបង្កើនការយល់ដឹងដល់សមាជិកសហគមន៍នេសាទ

ផែនការបង្កើនការយល់ដឹងដល់សមាជិកសហគមន៍នេសាទ ត្រូវបានរៀបចំខាងក្រោម៖

| ផែនការ | សកម្មភាព | ចំនួន | ការប៉ាន់ស្មានថវិកា (ដុល្លារ) | ថ្ងៃខែឆ្នាំចាប់ផ្តើម | ថ្ងៃខែឆ្នាំបញ្ចប់ |
|---|---|---|---|---|---|
| បង្កើនការយល់ដឹងដល់សមាជិកសហគមន៍នេសាទ | ផ្សព្វផ្សាយលក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុងសហគមន៍នេសាទ | ២ដង/ឆ្នាំ (៦ដងx២៥) | ១៥០ | កក្កដា ២០១៩ | មិថុនា ២០២២ |
| | ផ្សព្វផ្សាយកិច្ចព្រមព្រៀងសហគមន៍ | (១ដង/ឆ្នាំ ៣ដងx២៥) | ៧៥ | កក្កដា ២០១៩ | មិថុនា ២០២២ |
| | ផ្សព្វផ្សាយកន្លែងនេសាទ និងកន្លែងអភិរក្សរបស់សហគមន៍ | ១ដង/ឆ្នាំ (៣ដងx២៥) | ៧៥ | កក្កដា ២០១៩ | មិថុនា ២០២២ |
| | ផ្សព្វផ្សាយពីការប្រមូលប្រាក់សមាជិកភាព ភាគទានប្រចាំឆ្នាំ និងចំណូលចំណាយ | ១ដង/ឆ្នាំ (៣ដងx១០) | ៣០ | កក្កដា ២០១៩ | មិថុនា ២០២២ |
| | ផ្សព្វផ្សាយច្បាប់ជលផល និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ | ១ដង/ឆ្នាំ (៣ដងx២៥) | ៧៥ | កក្កដា ២០១៩ | មិថុនា ២០២២ |
| | យុទ្ធនាការផ្សព្វផ្សាយការយល់ដឹងអំពីសារប្រយោជន៍ធនធានជលផល | ១ដង/ឆ្នាំ (៣ដងx១០០) | ៣០០ | កក្កដា ២០១៩ | មិថុនា ២០២២ |
| | ប្រជុំផ្សព្វផ្សាយអំពីតួនាទីរបស់បុរសស្ត្រីក្នុងសហគមន៍នេសាទ និងការងារផ្ទះ សមភាពនិងសមធម៌យេនឌ័រ | ១ដង/ឆ្នាំ (៣ដងx២៥) | ៧៥ | កក្កដា ២០១៩ | មិថុនា ២០២២ |

### ឃ.៣.៤. ការផ្សព្វផ្សាយផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍

ការផ្សព្វផ្សាយផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ ត្រូវបានរៀបចំខាងក្រោម៖

| សកម្មភាព | ការប៉ាន់ស្មានថវិកា (ដុល្លារ) | ថ្ងៃខែឆ្នាំចាប់ផ្តើម | ថ្ងៃខែឆ្នាំបញ្ចប់ | អ្នកទទួលខុសត្រូវ |
|---|---|---|---|---|
| ផ្សព្វផ្សាយផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ទៅសមាជិកសហគមន៍តាមរយៈបុណ្យទាន មហាសន្និបាតប្រចាំឆ្នាំ | ១៥០ (៣លើកx៥០) | កក្កដា ២០១៩ | មិថុនា ២០២២ | គណៈកម្មាការសហគមន៍នេសាទ |
| បញ្ចូលផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ ទៅក្នុងកម្មវិធីវិនិយោគឃុំ | ៣០ (៣លើកx១០) | | | គណៈកម្មាការសហគមន៍នេសាទ |

### ឃ.៣.៥. ផែនការថវិកាទ្រទ្រង់សម្រាប់អភិវឌ្ឍន៍សហគមន៍

ផែនការថវិកាទ្រទ្រង់សម្រាប់អភិវឌ្ឍន៍សហគមន៍ ត្រូវបានរៀបចំខាងក្រោម៖

| ប្រភេទប្រាក់ចំណូល | សកម្មភាព | ថ្ងៃខែឆ្នាំ ចាប់ផ្តើម | ថ្ងៃខែឆ្នាំ បញ្ចប់ | ចំណូលសរុប (ដុល្លារ) | ផ្សេងៗ |
|---|---|---|---|---|---|
| ភាគទានពីសមាជិកសហគមន៍ | ចុះប្រមូលប្រាក់សមាជិកភាព | កក្កដា ២០១៩ | មិថុនា ២០២២ | ៣២,២៥ | ១.០០០ រៀល/នាក់ (១២៩នាក់) |
| ភាគទានប្រចាំឆ្នាំ | ចុះប្រមូលប្រាក់ភាគទានប្រចាំឆ្នាំ | | | ៥៨០,៥០ | ៦.០០០រៀល/នាក់ ក្នុងមួយឆ្នាំ (១២៩នាក់) |
| ភាគទានប្រចាំឆ្នាំពីជង្រុកស្រូវសហគមន៍ | ចុះប្រមូលប្រាក់ភាគទានប្រចាំឆ្នាំ | | | ៣៧,៥០ | ៥០.០០០ រៀល/ឆ្នាំ |
| ប្រាក់ចំណូលពីប្រភពផ្សេងៗ (អំណោយពីរាជរដ្ឋាភិបាល អំណោយពីសប្បុរសជន ជំនួយពីអង្គការជាតិ និងអង្គការដៃគូ) | • ទំនាក់ទំនងជាមួយស្ថាប័នជលផល<br>• សរសេរគម្រោងស្នើសុំពីអង្គការដៃគូ | | | ១១៦.៦៣៩,៧៥ | សរសេរគម្រោងចំណាយថវិកា ៥០០ ដុល្លារ |
| សរុប | | | | ១១៧.២៩០ | |

### ង. ការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ

ការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ ត្រូវបានរៀបចំខាងក្រោម៖

| សកម្មភាព | ថ្ងៃខែឆ្នាំ ចាប់ផ្តើម | ថ្ងៃខែឆ្នាំ បញ្ចប់ | អ្នកទទួលខុសត្រូវ | ផ្សេងៗ |
|---|---|---|---|---|
| ប្រជុំផ្ទៃក្នុង ប្រចាំត្រីមាសរបស់គណៈកម្មការសហគមន៍នេសាទ | កក្កដា ២០១៩ | មិថុនា ២០២២ | គណៈកម្មការ សហគមន៍នេសាទ | ១២០ (១២ដងx១០) |
| រៀបចំមហាសន្និបាតសហគមន៍ប្រចាំឆ្នាំ ដោយមានការចូលរួមពី ស្ត្រី ជនជាតិដើមភាគតិច និងជនជាតិភាគតិច | កក្កដា ២០១៩ | មិថុនា ២០២២ | គណៈកម្មការ សហគមន៍នេសាទ | ៦០០ (៣ដងx២០០) |

### ច. យុទ្ធសាស្ត្រ

ដើម្បីអនុវត្តផែនការឱ្យទទួលបានជោគជ័យ យុទ្ធសាស្ត្រមួយចំនួនត្រូវបានរៀបចំដូចខាងក្រោម៖

- បង្កើតគណៈកម្មការសម្រាប់អនុវត្តតាមដានត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តផែនការរួមមានសមាជិក គណៈកម្មការសហគមន៍នេសាទ ចាស់ទុំ សមាជិកសហគមន៍នេសាទ ដែលមានបទពិសោធន៍ និងចំណេះដឹងល្អ ជាពិសេសអំពីបញ្ហានេសាទ

- ស្នើសុំជំនួយបច្ចេកទេសពីរដ្ឋបាលជលផលមានសមត្ថកិច្ច ដើម្បីជួយផ្តល់យោបល់លើផែនការណា ដែលទាក់ទងនឹងបច្ចេកទេសជលផលដូចជាការធ្វើផែនការកន្លែងអភិរក្សត្រីមេពូជ ការរៀបចំកន្លែងអភិរក្សព្រៃលិចទឹក កន្លែងអភិរក្សជីវៈចម្រុះ ការស្តារព្រែក ការកំណត់ឧបករណ៍នេសាទ ការចិញ្ចឹមត្រី និងការរកថវិកាទ្រទ្រង់ជាដើម
- រៀបចំយុទ្ធសាស្ត្រទំនាក់ទំនងជាមួយស្ថាប័នជំនាញ អង្គការដៃគូ គម្រោង និងម្ចាស់ជំនួយ ដើម្បីទទួលបានការឧបត្ថម្ភគាំទ្រ និងថវិកាសម្រាប់ដំណើរការអនុវត្តផែនការ
- រៀបចំកម្មវិធីអនុវត្តផែនការតាមដំណាក់កាលនីមួយៗឱ្យបានជាក់លាក់
- ទាក់ទងជាមួយរដ្ឋបាលជលផល ដើម្បីសុំការគាំទ្រថវិកានិងជួយរកដៃគូសម្រាប់ទ្រទ្រង់ផែនការគ្រប់គ្រងសហគមន៍នេសាទ
- ផ្សព្វផ្សាយផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ ដល់សមាជិកសហគមន៍នេសាទ និងអ្នកពាក់ព័ន្ធសំខាន់ៗ ដើម្បីជំរុញការចូលរួម និងគាំទ្រដល់ការអនុវត្តផែនការគ្រប់គ្រងនេះ
- កៀរគរការចូលរួមចំណែករបស់សមាជិកសហគមន៍នេសាទ
- រៀបចំវិធានការចំពោះអ្នកនេសាទមកពីក្រៅសហគមន៍
- ពង្រឹងសមត្ថភាពបច្ចេកទេស និងគ្រប់គ្រងរបស់គណៈកម្មការសហគមន៍នេសាទ
- ចងក្រងក្រុមអ្នកនេសាទទៅតាមប្រភេទឧបករណ៍នេសាទដើម្បីចូលរួមអនុវត្តផែនការ
- បញ្ចូលផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ទៅក្នុងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគឃុំ
- ជ្រើសរើសស្ត្រីមេគ្រួសារ ជាសមាជិកចំនួនយ៉ាងតិច៧% ចូលរួមក្នុងសកម្មភាពទ្រទ្រង់ជីវភាពរស់នៅ
- អញ្ជើញស្ត្រីជាសមាជិកសហគមន៍នេសាទចូលរួមយ៉ាងតិច៤០% ក្នុងការបណ្តុះបណ្តាល សិក្ខាសាលា និងសកម្មភាព ទ្រទ្រង់ជីវភាពរស់នៅ និងវារីវប្បកម្ម
- កម្មករគ្មានជំនាញជាស្ត្រីជាសមាជិកសហគមន៍នេសាទ៤០%ចូលរួមសកម្មភាពហេដ្ឋារចនាសម្ព័ន្ធខ្នាតតូច
- អញ្ជើញស្ត្រីមេគ្រួសារ ស្ត្រីជនជាតិដើមភាគតិច និងជនជាតិភាគតិចជាសមាជិកសហគមន៍នេសាទ ចូលរួមប្រជុំ និងចូលរួមសកម្មភាពនានា និងចូលជាគណៈកម្មការរបស់សហគមន៍នេសាទ
- ជ្រើសរើសស្ត្រីជាសមាជិកសហគមន៍នេសាទ ៥០% ចូលរួមក្នុងសកម្មភាពគាំទ្រជីវភាព
- ផ្តល់ឱកាសស្ត្រី៥០%ជាសមាជិកសហគមន៍នេសាទចូលរួមក្នុងសកម្មភាពគាំទ្រជីវភាព និងទទួលផលប្រយោជន៍ពីគម្រោងក្នុងនោះស្ត្រីជាមេគ្រួសារ៧%
- លើកទឹកចិត្តស្ត្រីជាគណៈកម្មាការចូលរួមក្នុងការសម្រេចចិត្តនានា
- លើកទឹកចិត្តស្ត្រីជាគណៈកម្មាការមិនបោះបង់ចោលការងារ
- រៀបចំការប្រជុំឱ្យស្របនឹងពេលវេលារបស់ស្ត្រី ដែលមានលទ្ធភាពចូលរួម
- ជំរុញឱ្យមានស្ត្រីយ៉ាងតិច២៥% ជាសមាជិកគណកម្មាការសហគមន៍នេសាទ។

## តារាងសង្ខេបផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍វាលខ្យងរយៈពេល ៣ ឆ្នាំ (កក្កដា ២០១៩- មិថុនា ២០២២)

| ប្រភេទផែនការ | សកម្មភាព | លទ្ធផលរំពឹងទុក | ការប៉ាន់ស្មានថវិកា(ដុល្លារ) | ប្រភពថវិកា | ពេលចាប់ផ្តើម | ពេលបញ្ចប់ | ផ្សេងៗ |
|---|---|---|---|---|---|---|---|
| ឃ.១. ធនធានជលផល និងអេកូឡូស៊ី | | | | | | | |
| ឃ.១.១. ផែនការប្រើប្រាស់ឧបករណ៍នេសាទ | ផ្សព្វផ្សាយពីប្រភេទឧបករណ៍នេសាទដែលអនុញ្ញាត ទំហំ ពេលវេលា និងទីកន្លែងនេសាទនិងប្រភេទឧបករណ៍នេសាទហាមឃាត់ | ផែនការប្រើប្រាស់ឧបករណ៍នេសាទត្រូវបានផ្សព្វផ្សាយ ២ ដង ក្នុង០១ឆ្នាំ (រដូវបិទ និងបើកនេសាទ) | ១៥០ | រដ្ឋបាលជលផល អង្គការដៃគូ ស.នេសាទ | កក្កដា ២០១៩ | មិថុនា ២០២២ | |
| ឃ.១.២. ផែនការកំណត់ និងរៀបចំកន្លែងអភិរក្សសហគមន៍ | ដាក់ពោងនិងស្លាកសញ្ញាសំគាល់អន្លង់អភិរក្ស | ពោងនិងស្លាកសញ្ញាសំគាល់អភិរក្សចំនួន ៤ ត្រូវបានដាក់ | ៨០០ | រដ្ឋបាលជលផល អង្គការដៃគូ | កក្កដា ២០១៩ | ធ្នូ ២០១៩ | |
| | តម្លើងផ្ទាំងផ្សព្វផ្សាយអំពីច្បាប់ជលផល និងការអភិរក្ស | ផ្ទាំងផ្សព្វផ្សាយអំពីច្បាប់ជលផល និងការអភិរក្សចំនួន ២ ផ្ទាំងត្រូវបានតំលើង | ៤០០ | | កក្កដា ២០១៩ | ធ្នូ ២០១៩ | |
| | លែងកូនត្រីពូជ | កូនត្រីពូជរួមមានៈ ត្រីប្រា ត្រីឆ្ពិន ត្រីឆ្កោរ ត្រីខ្យា | ១.៥០០ | | កក្កដា ២០១៩ | មិថុនា ២០២២ | |
| ឃ.១.៣. ផែនការបោះបង្គោលព្រំប្រទល់ និងផ្ទាំងប៉ាណូផែនទីកន្លែងនេសាទសហគមន៍ | រៀបចំ និងលើកផ្ទាំងប៉ាណូផែនទីកន្លែងនេសាទសហគមន៍ | ផ្ទាំងប៉ាណូផែនទីកន្លែងនេសាទសហគមន៍២ផ្ទាំងត្រូវបានតម្លើង | ៣០០ | រដ្ឋបាលជលផល អង្គការដៃគូ | តុលា ២០១៩ | ធ្នូ ២០១៩ | |
| ឃ.១.៤. ផែនការគ្រប់គ្រងព្រៃលិចទឹក | ដាំព្រៃលិចទឹកតាមច្រាំងទន្លេ និងមាត់អូរ ចាប់ពីដើមភូមិដល់ចុងភូមិ | ព្រៃលិចទឹកដែលត្រូវការពារព្រមទាំងដាំឡើង វិញរួមមានៈ ក្រៃង រៃ គ្រស់ រាំង ទន្លា | ៣០០ | រដ្ឋបាលជលផល អង្គការដៃគូ | កក្កដា ២០១៩ | មិថុនា ២០២២ | |



th

| ប្រភេទផែនការ | សកម្មភាព | លទ្ធផលរំពឹងទុក | ការប៉ាន់ស្មានថវិកា(ដុល្លារ) | ប្រភពថវិកា | ពេលចាប់ផ្ដើម | ពេលបញ្ចប់ | ផ្សេងៗ |
|---|---|---|---|---|---|---|---|
| ឃ.២. គាំទ្រជីវភាពប្រជាពលរដ្ឋ | | | | | | | |
| ឃ.២.១. ផែនការមុខរបរបង្កើនប្រាក់ចំណូល | ចិញ្ចឹមមាន់តាមបច្ចេកទេសជាលក្ខណៈគ្រួសារ | ២០ គ្រួសារ | ១.០០០ | រដ្ឋបាលផលផល អង្គការដៃគូ | កក្កដា ២០១៩ | មិថុនា ២០២២ | |
| | ចិញ្ចឹមទាតាមបច្ចេកទេសជាលក្ខណៈគ្រួសារ | ១០ គ្រួសារ | ៥០០ | | កក្កដា ២០១៩ | មិថុនា ២០២២ | |
| | ចិញ្ចឹមគោតាមបច្ចេកទេសជាលក្ខណៈគ្រួសារ | ២៥ គ្រួសារ | ៧.៥០០ | | កក្កដា ២០១៩ | មិថុនា ២០២២ | |
| | ចិញ្ចឹមក្របីតាមបច្ចេកទេស ជាលក្ខណៈគ្រួសារ | ២៥ គ្រួសារ | ៧.៥០០ | | កក្កដា ២០១៩ | មិថុនា ២០២២ | |
| | ចិញ្ចឹមជ្រូកតាម បច្ចេកទេសជាលក្ខណៈគ្រួសារ | ៤០ គ្រួសារ | ៤.០០០ | | កក្កដា ២០១៩ | មិថុនា ២០២២ | |
| | រៀបចំសួនបន្លែតាមលក្ខណៈគ្រួសារ | ២០ គ្រួសារ | ១.០០០ | | កក្កដា ២០១៩ | មិថុនា ២០២២ | |
| | បណ្ដុះផ្សិត | ៣០ គ្រួសារ | ១.៥០០ | | កក្កដា ២០១៩ | មិថុនា ២០២២ | |
| | បណ្ដុះបណ្ដាលបច្ចេកទេសធ្វើស្រែនិងស្រែបង្ហាញ | ១០០ គ្រួសារ | ១០.០០០ | | កក្កដា ២០១៩ | មិថុនា ២០២២ | |
| ឃ.២.២. ផែនការអភិវឌ្ឍន៍វារីវប្បកម្ម | ចិញ្ចឹមត្រីអណ្ដែងក្នុងអាងតាមបច្ចេកទេសជាលក្ខណៈគ្រួសារ | សមាជិកសហគមន៍៥គ្រួសារមានជំនាញ ចិញ្ចឹមត្រី និងអាចរកប្រាក់ចំណូល ធ្វើឱ្យជីវភាពប្រសើរឡើង | ២.៥០០ | រដ្ឋបាលផលផល អង្គការដៃគូ | កក្កដា ២០១៩ | មិថុនា ២០២២ | |



th

| ប្រភេទផែនការ | សកម្មភាព | លទ្ធផលរំពឹងទុក | ការប៉ាន់ស្មានថវិកា(ដុល្លារ) | ប្រភពថវិកា | ពេលចាប់ផ្តើម | ពេលបញ្ចប់ | ផ្សេងៗ |
|---|---|---|---|---|---|---|---|
| ឃ.២.៣. ផែនការរៀបចំ និងពង្រឹងក្រុមសន្សំប្រាក់ | បង្កើតក្រុមសន្សំប្រាក់ចំនួន ១ ក្រុមបន្ថែម | ក្រុមសន្សំប្រាក់ចំនួន ១ ក្រុមត្រូវបានបង្កើតឡើង | ៣០០ | រដ្ឋបាលជលផល អង្គការដៃគូ | កក្កដា ២០១៩ | មិថុនា ២០២២ | |
| | ពង្រឹងក្រុមសន្សំប្រាក់ដែលមានស្រាប់ | ក្រុមសន្សំ ដែលមានស្រាប់ចំនួន១ក្រុម ត្រូវបានពង្រឹង | ២០០ | រដ្ឋបាលជលផល អង្គការដៃគូ | កក្កដា ២០១៩ | មិថុនា ២០២២ | |
| ឃ.២.៤. ផែនការសេវាសហគមន៍ និងហេដ្ឋារចនាសម្ព័ន្ធ | ជួសជុលផ្លូវលំក្នុងភូមិ | ផ្លូវលំ១ខ្សែប្រវែង ៤.០០០មត្រូវបានជួសជុល និងប្រើជាប្រយោជន៍រួមរបស់សហគមន៍ | ៤០.០០០ | រដ្ឋបាលជលផល អង្គការដៃគូ | កក្កដា ២០១៩ | មិថុនា ២០២២ | |
| | ដាក់លូកាត់ផ្លូវ | លូកាត់ទទឹងផ្លូវចំនួន ១ កន្លែងត្រូវបានដាក់ឡើងវិញ | ១.៥០០ | រដ្ឋបាលជលផល អង្គការដៃគូ | កក្កដា ២០១៩ | មិថុនា ២០២២ | |
| | សាងសង់ផ្សារសហគមន៍ | ផ្សារសហគមន៍ចំនួន ១ កន្លែងត្រូវបានសាងសង់ និងប្រើជាប្រយោជន៍រួមរបស់សហគមន៍ | ៥.០០០ | រដ្ឋបាលជលផល អង្គការដៃគូ | កក្កដា ២០១៩ | មិថុនា ២០២២ | |
| | សាងសង់សាលាមតេយ្យ | សាលាមតេយ្យចំនួន ១ ខ្នងត្រូវបានសាងសង់ | ១០.០០០ | រដ្ឋបាលជលផល អង្គការដៃគូ | កក្កដា ២០១៩ | មិថុនា ២០២២ | |
| | សាងសង់បង្គន់អនាម័យក្នុងសាលាមត្តេយ្យ | ២ បង្គន់ | ៤០០ | | កក្កដា ២០១៩ | មិថុនា ២០២២ | |
| ឃ.៣. ការគ្រប់គ្រង | | | | | | | |
| ឃ.៣.១. ផែនការសកម្មភាពចុះល្បាតទប់ស្កាត់បទល្មើស | សហគមន៍ចុះល្បាត | ៨ដង/ខែ | ៧.២០០ | រដ្ឋបាលជលផល អង្គការដៃគូ | កក្កដា ២០១៩ | មិថុនា ២០២២ | |
| | ផ្តល់សម្ភារល្បាត | ១ឈុត | ១.០០០ | | កក្កដា ២០១៩ | កញ្ញា ២០១៩ | |
| | ទិញទូកស្ពាច់និងម៉ាស៊ីន | ២គ្រឿង (១តូច ១ធំ) | ៣.០០០ | | កក្កដា | កញ្ញា | |



th

| ប្រភេទផែនការ | សកម្មភាព | លទ្ធផលរំពឹងទុក | ការប៉ាន់ស្មានថវិកា(ដុល្លារ) | ប្រភពថវិកា | ពេលចាប់ផ្តើម | ពេលបញ្ចប់ | ផ្សេងៗ |
|---|---|---|---|---|---|---|---|
| | | | | | ២០១៩ | ២០១៩ | |
| | ទិញប្រេងសម្រាប់ល្បាត | ៨០លីត្រ/១ខែ | ២.៨៨០ | | កក្កដា ២០១៩ | មិថុនា ២០២២ | |
| | ជួសជុលនិងថែទាំទូក និងម៉ាស៊ីន | ២ដង/ឆ្នាំ | ៦០០ | | កក្កដា ២០១៩ | មិថុនា ២០២២ | |
| | សាងសង់ទីស្នាក់ការសហគមន៍ | ស្នាក់ការចំនួន១ ត្រូវបានសាងសង់ | ៣.០០០ | | សីហា ២០១៩ | ធ្នូ ២០១៩ | |
| ឃ.៣.២. ផែនការពង្រឹងគណៈកម្មការសហគមន៍នេសាទ | ប្រជុំប្រចាំខែរបស់គណៈកម្មការសហគមន៍នេសាទ | ១ដង/១ខែ | ៣៦០ | រដ្ឋបាលជលផល អង្គការដៃគូ សហគមន៍នេសាទ | កក្កដា ២០១៩ | មិថុនា ២០២២ | ប្រជុំរៀងរាល់ខែ |
| | ចូលរួមប្រជុំប្រចាំខែជាមួយក្រុមប្រឹក្សាឃុំ | ១ដង/១ខែ | ៣៦០ | | កក្កដា ២០១៩ | មិថុនា ២០២២ | ប្រជុំរៀងរាល់ខែ |
| | បណ្តុះបណ្តាលអំពីរបៀបធ្វើកំណត់ហេតុ សរសេរលិខិតរដ្ឋបាល របាយការណ៍ និងរៀបចំទុកដាក់ឯកសារ | ១លើក/១ឆ្នាំ | ៦០ | | កក្កដា ២០១៩ | មិថុនា ២០២២ | ៣វគ្គ/៣ឆ្នាំ |
| | បណ្តុះបណ្តាលអំពីការដោះស្រាយទំនាស់ | ១លើក/១ឆ្នាំ | ៦០ | | កក្កដា ២០១៩ | មិថុនា ២០២២ | ៣វគ្គ/៣ឆ្នាំ |
| | បណ្តុះបណ្តាលអំពីភាពជាអ្នកដឹកនាំ | ១លើក/១ឆ្នាំ | ៦០ | | កក្កដា ២០១៩ | មិថុនា ២០២២ | ៣វគ្គ/៣ឆ្នាំ |
| | បណ្តុះបណ្តាលអំពីការរៀបចំផែនការសកម្មភាពការងារ | ១លើក/១ឆ្នាំ | ៦០ | | កក្កដា ២០១៩ | មិថុនា ២០២២ | ៣វគ្គ/៣ឆ្នាំ |
| | បណ្តុះបណ្តាលអំពីការកត់ត្រា | ១លើក/១ឆ្នាំ | ៦០ | | កក្កដា | មិថុនា | ៣វគ្គ/៣ឆ្នាំ |

| ប្រភេទផែនការ | សកម្មភាព | លទ្ធផលរំពឹងទុក | ការប៉ាន់ស្មានថវិកា(ដុល្លារ) | ប្រភពថវិកា | ពេលចាប់ផ្តើម | ពេលបញ្ចប់ | ផ្សេងៗ |
|---|---|---|---|---|---|---|---|
| | ចំណាយចំណូល | | | | ២០១៩ | ២០២២ | |
| | បណ្តុះបណ្តាលអំពីការសរសេរសំណើថវិកា | ១លើក/១ឆ្នាំ | ៦០ | | កក្កដា ២០១៩ | មិថុនា ២០២២ | ៣វគ្គ/៣ឆ្នាំ |
| យ.៣.៣. ផែនការបង្កើនការយល់ដឹងដល់សមាជិកសហគមន៍នេសាទ | ផ្សព្វផ្សាយលក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុងសហគមន៍នេសាទ | ២ដង/ឆ្នាំ | ១៥០ | រដ្ឋបាលជលផល អង្គការដៃគូ សហគមន៍ | កក្កដា ២០១៩ | មិថុនា ២០២២ | ១ឆ្នាំ ២ដង |
| | ផ្សព្វផ្សាយកិច្ចព្រមព្រៀងសហគមន៍ | ១ដង/ឆ្នាំ | ៧៥ | | កក្កដា ២០១៩ | មិថុនា ២០២២ | |
| | ផ្សព្វផ្សាយកន្លែងនេសាទនិងកន្លែងអភិរក្សរបស់ សហគមន៍ | ១ដង/ឆ្នាំ | ៧៥ | | កក្កដា ២០១៩ | មិថុនា ២០២២ | |
| | ផ្សព្វផ្សាយពីការប្រមូលប្រាក់បដិភាគ | ១ដង/ឆ្នាំ | ៣០ | | កក្កដា ២០១៩ | មិថុនា ២០២២ | |
| | ផ្សព្វផ្សាយច្បាប់ជលផល និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ | ១ដង/ឆ្នាំ | ៧៥ | | កក្កដា ២០១៩ | មិថុនា ២០២២ | |
| | យុទ្ធនាការផ្សព្វផ្សាយការយល់ដឹងអំពីសារប្រយោជន៍ធនធានជលផល | ១ដង/ឆ្នាំ | ៣០០ | | កក្កដា ២០១៩ | មិថុនា ២០២២ | |
| | ប្រជុំផ្សព្វផ្សាយអំពីតួនាទីរបស់បុរសស្ត្រីក្នុងសហគមន៍នេសាទ និងការងារផ្ទះ សមភាពនិងសមធម៌យេនឌ័រ | ១ដង/ឆ្នាំ | ៧៥ | | កក្កដា ២០១៩ | មិថុនា ២០២២ | |
| យ.៣.៤. ការផ្សព្វផ្សាយផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ | ផ្សព្វផ្សាយផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ទៅសមាជិកសហគមន៍តាមរយៈបុណ្យទានមហាសន្និបាតប្រចាំឆ្នាំ | ១ដង/ឆ្នាំ | ១៥០ | រដ្ឋបាលជលផល អង្គការដៃគូ សហគមន៍នេសាទ | កក្កដា ២០១៩ | មិថុនា ២០២២ | |



th

| ប្រភេទផែនការ | សកម្មភាព | លទ្ធផលរំពឹងទុក | ការប៉ាន់ស្មានថវិកា(ដុល្លារ) | ប្រភពថវិកា | ពេលចាប់ផ្ដើម | ពេលបញ្ចប់ | ផ្សេងៗ |
|---|---|---|---|---|---|---|---|
| | បញ្ចូលផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ ទៅក្នុងកម្មវិធីវិនិយោគឃុំ | ១ដង/ឆ្នាំ | ៣០ | គណៈកម្មការ | កក្កដា ២០១៩ | មិថុនា ២០២២ | |
| ឃ.៣.៥. ផែនការថវិកាទ្រទ្រង់សម្រាប់អភិវឌ្ឍន៍សហគមន៍ | ភាគទានពីសមាជិកសហគមន៍ | សមាជិកសហគមន៍បានបង់ភាគទានសមាជិកភាព | ៣២,២៥ | សហគមន៍នេសាទ | កក្កដា ២០១៩ | មិថុនា ២០២២ | |
| | ភាគទានប្រចាំឆ្នាំពីសមាជិកសហគមន៍នេសាទ | ១ឆ្នាំម្តង | ៥៨០,៥០ | | កក្កដា ២០១៩ | មិថុនា ២០២២ | |
| | ភាគទានប្រចាំឆ្នាំពីជង្រុកស្រូវសហគមន៍ | ១ឆ្នាំម្តង | ៣៧,៥០ | | កក្កដា ២០១៩ | មិថុនា ២០២២ | |
| | ប្រាក់ចំណូលពីប្រភពផ្សេងៗ (អំណោយពីរាជរដ្ឋាភិបាល អំណោយពីសប្បុរសជន ជំនួយពីអង្គការជាតិ និងអង្គការដៃគូ) | សហគមន៍នេសាទទទួលបានកញ្ចប់ថវិកាពីប្រភពផ្សេងៗ | ១១៦.៦៣៩,៧៥ | រដ្ឋបាលជលផល អង្គការដៃគូ | កក្កដា ២០១៩ | មិថុនា ២០២២ | |
| ង. ការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ | ប្រជុំផ្ទៃក្នុង ប្រចាំត្រីមាសរបស់គណៈកម្មការសហគមន៍នេសាទ | ៤ដង/ឆ្នាំ | ១២០ | រដ្ឋបាលជលផល អង្គការដៃគូ | កក្កដា ២០១៩ | មិថុនា ២០២២ | |
| | រៀបចំមហាសន្និបាតសហគមន៍ប្រចាំឆ្នាំ ដោយមានការចូលរួមពីស្ត្រី ជនជាតិដើមភាគតិច និងជនជាតិភាគតិច | ១ដង/ឆ្នាំ | ៦០០ | រដ្ឋបាលជលផល អង្គការដៃគូ | កក្កដា ២០១៩ | មិថុនា ២០២២ | |

សម្គាល់៖ សហគមន៍នេសាទនៅខេត្តក្រចេះនិងស្ទឹងត្រែងដែលគម្រោងគាំទ្របានចាប់ផ្តើមរៀបចំផែនការគ្រប់គ្រង នៅត្រីមាសទី៤ ឆ្នាំ២០១៨។

## តារាងកម្មវិធីការងារប្រចាំឆ្នាំ (កក្កដា ២០១៩- មិថុនា ២០២២)

| សកម្មភាព | ពេលវេលា | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | ២០១៩ | | | | | | ២០២០ | | | | | | | | | | | | ២០២១ | | | | | | | | | | | | ២០២២ | | | | | |
| | ៧ | ៨ | ៩ | ១០ | ១១ | ១២ | ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | ១០ | ១១ | ១២ | ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | ១០ | ១១ | ១២ | ១ | ២ | ៣ | ៤ | ៥ | ៦ |
| ឃ.១. ធនធានជលផល និងអេកូឡូស៊ី | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ឃ.១.១. ផែនការប្រើប្រាស់ឧបករណ៍នេសាទ | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ផ្សព្វផ្សាយពីប្រភេទឧបករណ៍នេសាទដែលអនុញ្ញាត ទំហំ ពេលវេលា និងទីកន្លែងនេសាទនិងប្រភេទឧបករណ៍នេសាទហាមឃាត់ | | | | X | | | | | | | X | | | | | X | | | | | | | X | | | | | X | | | | | | | X | |
| ឃ.១.២. ផែនការកំណត់ និងរៀបចំកន្លែងអភិរក្សសហគមន៍ | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ដាក់ពោងនិងស្លាកសញ្ញាសំគាល់អន្លង់អភិរក្ស | X | X | X | X | X | X | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| តម្លើងផ្ទាំងផ្សព្វផ្សាយអំពីច្បាប់ជលផល និងការអភិរក្ស | X | X | X | X | X | X | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| លែងកូនត្រីពូជ | X | | | | | | | | | | | | X | | | | | | | | | | | | X | | | | | | | | | | | |
| ឃ.១.៣. ផែនការបោះបង្គោលព្រំប្រទល់ និងផ្ទាំងប៉ាណូផែនទីកន្លែងនេសាទសហគមន៍ | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| រៀបចំ និងលើកផ្ទាំងប៉ាណូផែនទីកន្លែងនេសាទសហគមន៍ | | | | X | X | X | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ឃ.១.៤. ផែនការគ្រប់គ្រងព្រៃលិចទឹក | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ដាំព្រៃលិចទឹកតាមច្រាំងទន្លេមាត់អូរ និងមាត់អូរចាប់ពីដើមភូមិដល់ចុងភូមិ | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X |



th

| សកម្មភាព | ពេលវេលា | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | ២០១៩ | | | | | | ២០២០ | | | | | | | | | | | | ២០២១ | | | | | | | | | | | | ២០២២ | | | | | |
| | ៧ | ៨ | ៩ | ១០ | ១១ | ១២ | ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | ១០ | ១១ | ១២ | ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | ១០ | ១១ | ១២ | ១ | ២ | ៣ | ៤ | ៥ | ៦ |
| ឃ.២. គាំទ្រជីវភាពប្រជាពលរដ្ឋ | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ឃ.២.១. ផែនការមុខរបរបង្កើនប្រាក់ចំណូល | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ចិញ្ចឹមមាន់តាមបច្ចេកទេសជាលក្ខណៈគ្រួសារ | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X |
| ចិញ្ចឹមទាតាមបច្ចេកទេសជាលក្ខណៈគ្រួសារ | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X |
| ចិញ្ចឹមគោតាមបច្ចេកទេសជាលក្ខណៈគ្រួសារ | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X |
| ចិញ្ចឹមក្របី | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X |
| ចិញ្ចឹមជ្រូក | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X |
| រៀបចំសួនបន្លែ | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X |
| បណ្តុះ ផ្សិត | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X |
| បណ្តុះបណ្តាលបច្ចេកទេសធ្វើស្រែ និងស្រែបង្ហាញ | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X |
| ឃ.២.២. ផែនការអភិវឌ្ឍន៍វារីវប្បកម្ម | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ចិញ្ចឹមត្រីអណ្តែងក្នុងអាងតាមបច្ចេកទេសជាលក្ខណៈគ្រួសារ | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X |
| ឃ.២.៣. ផែនការរៀបចំ និងពង្រឹងក្រុមសន្សំប្រាក់ | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| បង្កើតក្រុមសន្សំប្រាក់បន្ថែម | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X |
| ពង្រឹងក្រុមសន្សំប្រាក់ដែលមានស្រាប់ | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X |

| សកម្មភាព | ពេលវេលា | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | ២០១៩ | | | | | | ២០២០ | | | | | | | | | | | | ២០២១ | | | | | | | | | | | | ២០២២ | | | | | |
| | ៧ | ៨ | ៩ | ១០ | ១១ | ១២ | ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | ១០ | ១១ | ១២ | ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | ១០ | ១១ | ១២ | ១ | ២ | ៣ | ៤ | ៥ | ៦ |
| **ឃ.២.៤. ផែនការសេវាសហគមន៍ និងហេដ្ឋារចនាសម្ព័ន្ធ** | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ជួសជុលផ្លូវលំក្នុងភូមិ | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X |
| ដាក់លូកាត់ផ្លូវ | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X |
| សាងសង់ផ្សារសហគមន៍ | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X |
| សាងសង់សាលាមតេយ្យ | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X |
| សាងសង់បង្គន់អនាម័យក្នុងសាលាមតេយ្យ | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X |
| **ឃ.៣. ការគ្រប់គ្រង** | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| **ឃ.៣.១. ផែនការសកម្មភាពចុះល្បាតទប់ស្កាត់បទល្មើស** | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| សហគមន៍ចុះល្បាត | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X |
| ផ្តល់សម្ភារល្បាត | X | X | X | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ទិញទូកស្នាច់ និងម៉ាស៊ីន | X | X | X | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ទីញប្រេងសម្រាប់ល្បាត | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X |
| ជួសជុលនិងថែទាំទូក ម៉ាស៊ីន | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X |
| សាងសង់ទីស្នាក់ការសហគមន៍ | | X | X | X | X | X | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| **ឃ.៣.២. ផែនការពង្រឹងគណៈកម្មការសហគមន៍នេសាទ** | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ប្រជុំប្រចាំខែរបស់គណៈកម្មការសហគមន៍នេសាទ | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X |
| ចូលរួមប្រជុំប្រចាំខែជាមួយក្រុមប្រឹក្សាឃុំ | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X |



th

| សកម្មភាព | ពេលវេលា | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | ២០១៩ | | | | | | ២០២០ | | | | | | | | | | | | ២០២១ | | | | | | | | | | | | ២០២២ | | | | | |
| | ៧ | ៨ | ៩ | ១០ | ១១ | ១២ | ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | ១០ | ១១ | ១២ | ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | ១០ | ១១ | ១២ | ១ | ២ | ៣ | ៤ | ៥ | ៦ |
| បណ្តុះបណ្តាលអំពីរបៀបធ្វើកំណត់ហេតុ សរសេរលិខិតរដ្ឋបាលរបាយការណ៍ និងរៀបចំទុកឯកសារ | | | | | | | | | | | | X | | | | | | | | | | | | X | | | | | | | | | | | | X |
| បណ្តុះបណ្តាលអំពីការដោះស្រាយទំនាស់ | | | X | | | | | | | | | | | | X | | | | | | | | | | | | X | | | | | | | | | |
| បណ្តុះបណ្តាលអំពីភាពជាអ្នកដឹកនាំ | | | | | X | | | | | | | | | | | X | | | | | | | | | | | | X | | | | | | | | |
| បណ្តុះបណ្តាលអំពីការរៀបចំផែនការសកម្មភាពការងារ | | | | | | X | | | | | | | | | | | X | | | | | | | | | | | | X | | | | | | | |
| បណ្តុះបណ្តាលអំពីការកត់ត្រាចំណាយចំណូល | | | | | | | X | | | | | | | | | | | X | | | | | | | | | | | | X | | | | | | |
| បណ្តុះបណ្តាលអំពីការសរសេរសំណើថវិកា | | | | | | | | X | | | | | | | | | | | X | | | | | | | | | | | | X | | | | | |
| ឃ.៣.៣. ផែនការបង្កើនការយល់ដឹងដល់សមាជិកសហគមន៍នេសាទ | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ផ្សព្វផ្សាយលក្ខន្តិកៈ និងបទបញ្ជាផ្ទៃ ក្នុងសហគមន៍នេសាទ | | X | | | | | | | | | X | | | X | | | | | | | | | X | | | X | | | | | | | | | X | |
| ផ្សព្វផ្សាយកិច្ចព្រមព្រៀងសហគមន៍នេសាទ | | X | | | | | | | | | | | | X | | | | | | | | | | | | X | | | | | | | | | | |
| ផ្សព្វផ្សាយកន្លែងនេសាទនិងកន្លែងអភិរក្សរបស់សហគមន៍ | | X | | | | | | | | | | | | X | | | | | | | | | | | | X | | | | | | | | | | |
| ផ្សព្វផ្សាយពីការប្រមូលប្រាក់ប្រចាំឆ្នាំ | | | | | | | | X | | | | | | | | | | | | X | | | | | | | | | | | | X | | | | |



th

| សកម្មភាព | ពេលវេលា | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | ២០១៩ | | | | | | ២០២០ | | | | | | | | | | | | ២០២១ | | | | | | | | | | | | ២០២២ | | | | | |
| | ៧ | ៨ | ៩ | ១០ | ១១ | ១២ | ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | ១០ | ១១ | ១២ | ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | ១០ | ១១ | ១២ | ១ | ២ | ៣ | ៤ | ៥ | ៦ |
| ផ្សព្វផ្សាយច្បាប់ជលផល និងលិខិតបទដ្ឋានគតិយុទ្ធពាក់ព័ន្ធ | | | X | | | | | | | | | | | | X | | | | | | | | | | | | X | | | | | | | | | |
| យុទ្ធនាការផ្សព្វផ្សាយការយល់ដឹងអំពីសារប្រយោជន៍ធនធានជលផល | | X | | | | | | | | | | | | X | | | | | | | | | | | | X | | | | | | | | | | |
| ប្រជុំផ្សព្វផ្សាយអំពីតួនាទីរបស់បុរស ស្ត្រីក្នុងសហគមន៍នេសាទ សមភាពនិងសមធម៌យេនឌ័រ | | | | | X | | | | | | | | | | | X | | | | | | | | | | | | X | | | | | | | | |
| ឃ.៣.៤. ការផ្សព្វផ្សាយផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ផ្សព្វផ្សាយផែនការគ្រប់គ្រងកន្លែង | | | | | | X | | | | | | | | | | | | X | | | | | | | | | | | | X | | | | | | |
| បញ្ចូលផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ទៅក្នុងកម្មវិធីវិនិយោគឃុំ | X | X | | | | | | | | | | | X | X | | | | | | | | | | | X | X | | | | | | | | | | |
| ឃ.៣.៥. ផែនការថវិកាទ្រទ្រង់សម្រាប់អភិវឌ្ឍន៍សហគមន៍ | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ភាគទានពីសមាជិកសហគមន៍ | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X |
| ភាគទានប្រចាំឆ្នាំ | | | | | | | | X | | | | | | | | | | | | X | | | | | | | | | | | | X | | | | |
| ភាគទានប្រចាំឆ្នាំពីផង្រុកស្រូវសហគមន៍ | | | | | | | X | | | | | | | | | | | | X | | | | | | | | | | | | X | | | | | |
| ប្រាក់ចំណូលពីប្រភពផ្សេងៗ | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X |
| ង. ការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ប្រជុំផ្ទៃក្នុង ប្រចាំត្រីមាសរបស់គណៈកម្មការសហគមន៍នេសាទ | | | X | | | X | | | X | | | X | | | X | | | X | | | X | | | X | | | X | | | X | | | X | | | X |

| សកម្មភាព | ពេលវេលា | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | ២០១៩ | | | | | | ២០២០ | | | | | | | | | | | | ២០២១ | | | | | | | | | | | | ២០២២ | | | | | |
| | ៧ | ៨ | ៩ | ១០ | ១១ | ១២ | ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | ១០ | ១១ | ១២ | ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | ១០ | ១១ | ១២ | ១ | ២ | ៣ | ៤ | ៥ | ៦ |
| រៀបចំមហាសន្និបាតសហគមន៍ប្រចាំឆ្នាំ ដោយមានការចូលរួមពីស្ត្រី ជនជាតិដើមភាគតិច និងជនជាតិភាគតិច | | | | | | x | | | | | | | | | | | | x | | | | | | | | | | | | x | | | | | | |

សូមគោរពជូន
លោកមេឃុំកំពង់ចាម
"ដើម្បីជូនពិនិត្យ និងសម្រួល"
ថ្ងៃ........ខែ........ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣
ភូមិសំភិន ថ្ងៃទី២៤ ខែ កក្កដា ឆ្នាំ២០១៩
ប្រធានគណៈកម្មការសហគមន៍នេសាទវាលខ្សង

ស្រីតាន់

លេខ: ........
បានឃើញ និងគោរពជូន
លោកនាយសង្កាត់រដ្ឋបាលជលផលសំបូរ
"ដើម្បីជូនពិនិត្យ និងសម្រួល"
ថ្ងៃ........ខែ........ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣
ឃុំកំពង់ចាម ថ្ងៃទី ........ ខែ កក្កដា ឆ្នាំ២០១៩
មេឃុំកំពង់ចាម

ឈើត.ណាន

លេខ: ........
បានឃើញ និងគោរពជូន
លោកនាយផ្នែករដ្ឋបាលជលផលកាំពី
"ដើម្បីជូនពិនិត្យ និងសម្រួល"
ថ្ងៃ........ខែ........ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣
សំបូរ ថ្ងៃទី២៥ ខែ កក្កដា ឆ្នាំ២០១៩
នាយសង្កាត់រដ្ឋបាលជលផលសំបូរ

លេខ :..........
បានឃើញ និងគោរពជូន
ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកជា
ប្រធានរដ្ឋបាលជលផល
"ដើម្បីជូនពិនិត្យ និងសម្រេចដោយអនុគ្រោះ"
ថ្ងៃ.......... ខែ..........ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣
ក្រចេះ ថ្ងៃទី ៣១ ខែ កក្កដា ឆ្នាំ២០១៩
ប្រធាន
មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តក្រចេះ

ទ្រី-សុភក្តិ

លេខ :..........
បានឃើញ និងគោរពជូន
លោកប្រធាន
មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តក្រចេះ
"ដើម្បីជូនពិនិត្យ និងសម្រួល"
ថ្ងៃ.......... ខែ..........ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣
ក្រចេះ ថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ២០១៩
នាយខណ្ឌរដ្ឋបាលជលផលក្រចេះ

សៀន គិន

លេខ :..........
បានឃើញ និងគោរពជូន
លោកនាយខណ្ឌរដ្ឋបាលជលផលក្រចេះ
"ដើម្បីជូនពិនិត្យ និងសម្រួល"
ថ្ងៃ.......... ខែ.......... ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣
កាំពី ថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ២០១៩
ជ.នាយផ្នែករដ្ឋបាលជលផលកាំពី

ទូ សុវណ្ណា

លេខ :..........
បានឃើញ និងឯកភាព
ថ្ងៃ.......... ខែ..........ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣
រាជធានីភ្នំពេញ ថ្ងៃទី ៣១ ខែ កក្កដា ឆ្នាំ២០១៩
ប្រតិភូរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកជា
ប្រធានរដ្ឋបាលជលផល

អេង ជាសាន